**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**កំពង់ផែស្វយ័តភ្នំពេញ**

លេខ: ...១១៥៩.........ក.ស.ភ.

ថ្ងៃ ព្រហ ១៣កើត ខែ មាឃ ឆ្នាំ រកា ព.ស.២៥៦០
រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ ២ គ.ស.២០១៧

# សេចក្តីប្រកាសព័ត៌មាន

**កំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ.)** មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ភាគហ៊ុនិកដែលកាន់កាប់មូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោតប្រភេទ "ក" របស់ ក.ស.ភ. ទាំងអស់មេត្តាជ្រាបថា៖ យោងតាមកិច្ចពិភាក្សាលើលទ្ធផលនៃការប៉ាន់ស្មានប្រាក់ចំណេញសម្រាប់ឆ្នាំ២០១៦ របស់ ក.ស.ភ. ក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី៣ អាណត្តិទី៦ នាថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ក.ស.ភ. អាចនឹងសម្រេចលទ្ធផលអាជីវកម្មស្របតាមផែនការឆ្នាំ២០១៦។ ដូចនេះ ក.ស.ភ. អាចនឹងមានលទ្ធភាពបែងចែកភាគលាភឆ្នាំ២០១៦ ជូនភាគហ៊ុនិកប្រភេទ "ក" របស់ ក.ស.ភ. ក្នុងអត្រាអប្បបរមា ៥% ដែលមានចំនួន ១.០៥៩.០៣៩.០០០ រៀល (មួយប៊ីលាន ហាសិបប្រាំបួនលាន សាមសិបប្រាំបួនពាន់រៀលគត់)។ ការសម្រេចបែងចែកភាគលាភឆ្នាំ២០១៦ នឹងធ្វើឡើងក្រោយពីមានការអនុម័តដោយក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុឆ្នាំ២០១៦ របស់ ក.ស.ភ. ដែលបានធ្វើសវនកម្មដោយសវនកររងករាជ្យ (KPMG) ក្នុងអំឡុងត្រីមាសទី១ ឆ្នាំ២០១៧។

ជាមួយគ្នានេះដែរ ភាគលាភឆ្នាំ២០១៥ ដែលបានបង្គរទុក ក៏នឹងត្រូវទូទាត់ក្នុងអំឡុងត្រីមាសទី១ ឆ្នាំ២០១៧ ខាងមុខនេះផងដែរ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមភាគហ៊ុនិកប្រភេទ "ក" និងសាធារណជនមេត្តាជ្រាបជាព័ត៌មាន។

**កំពង់ផែស្វយ័តភ្នំពេញ**

ទីស្នាក់ការកណ្តាល: អគារលេខ ៦៤៩ តិរវិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ/ទូរសារ (៨៥៥) ៤២៧ ៨០២ Email: ppapmpwt@online.com.kh / info@ppap.com.kh